# ការអនុវត្តអនុសាសន៍នៃដំណើរការពិនិត្យជាសកលតាមកាលកំណត់ ៖ វឌ្ឍនភាពរយៈពេល ៣ ឆ្នាំ នៃការអនុវត្តអនុសាសន៍ដែលទទួលយកទាក់ទងនឹងនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញទំនោរយេនឌ័រ និង/ឬលក្ខណៈភេទ

## និយមន័យ



ដំណើរការពិនិត្យជាសកលតាមកាលកំណត់ («យូភីអ») គឺជាយន្តការនៃអង្គការសហប្រជាជាតិដែលពិនិត្យលើការអនុវត្តសិទ្ធិមនុស្សនៃរដ្ឋជាសមាជិកទាំងអស់នៅលើពិភពលោក។ ក្នុងអំឡុងពេល យូភីអ រដ្ឋដែលស្ថិតក្រោមការពិនិត្យពន្យល់អំពីលទ្ធផលដែលរដ្ឋសម្រេចបានចំពោះការគោរពសិទ្ធិមនុស្ស ខណៈដែលរដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិផ្សេងទៀតផ្តល់អនុសាសន៍អំពីវិធីដែលរដ្ឋអាចធ្វើឱ្យសិទ្ធិមនុស្សបានប្រសើរ។

## យូភីអ ជុំទី៣ របស់ប្រទេសកម្ពុជា

លទ្ធផលនៃ យូភីអ ជុំទី៣ របស់ប្រទេសកម្ពុជា នៅឆ្នាំ ២០១៩ ៖

- ក្នុងខែមករា ឆ្នាំ២០១៩ ប្រទេសកម្ពុជាបានទទួលអនុសាសន៍ចំនួន១៩៨ ពីបណ្តាប្រទេសជាសមាជិកនៃអង្គការសហប្រជាជាតិចំនួន៧៣ ទាក់ទងនឹងបញ្ហាសិទ្ធិមនុស្សក្នុងវិស័យផ្សេងៗ
- ក្នុងខែកក្កដា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា («រដ្ឋាភិបាល») បានសម្រេចទទួលយកអនុសាសន៍ចំនួន ១៧៣ ទាក់ទងនឹងបញ្ហាសិទ្ធិមនុស្សក្នុងវិស័យជាច្រើន ដូចជា សិទ្ធិដីធ្លី សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ការការពារអ្នកការពារសិទ្ធិមនុស្ស សិទ្ធិកុមារ សិទ្ធិស្ត្រី សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញទំនោរយេនឌ័រ និង/ឬលក្ខណៈភេទ។

ក្នុងចំណោមអនុសាសន៍ដែលកម្ពុជាបានទទួលយកទាំងនោះ មានអនុសាសន៍ចំនួន៩ លើកឡើងជាក់លាក់អំពីសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា។ រដ្ឋាភិបាលកម្ពុជាបានទទួលយកអនុសាសន៍ទាំង ៩ ដោយធ្វើការប្តេជ្ញាចិត្តផ្នែកនយោបាយក្នុងការអនុវត្តអនុសាសន៍ទាំងនេះឱ្យបានមុនការពិនិត្យនៅជុំបន្ទាប់។

១.បង្កើតច្បាប់ប្រឆាំងការរើសអើងដែលធានានិងហាមឃាត់យ៉ាងជាក់លាក់នូវរាល់ប្រភេទនៃការរើសអើងដោយសារនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងលក្ខណៈភេទ។

២. បង្កើតច្បាប់ទទួលស្គាល់យេនឌ័រ ។

៣. វិសោធនកម្មរដ្ឋធម្មនុញ្ញដើម្បីធានាឱ្យមានសមភាពអាពាហ៍ពិពាហ៍សម្រាប់គូស្រករភេទដូចគ្នា។

៤.ពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល ដើម្បីអនុម័តច្បាប់ និងគោលនយោបាយដែលគ្រប់ជ្រុងជ្រោយប្រឆាំងនឹងការរើសអើង និងអំពើហិង្សាដោយសារនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ និងធានាការអនុវត្តច្បាប់ និងគោលនយោបាយទាំងនេះនៅក្នុងស្ថាប័នសាធារណៈទាំងអស់ ជាពិសេស ក្នុងវិស័យអប់រំ សុខាភិបាល និងការងារ។

៥.ធ្វើវិសោធនកម្មមាត្រា៤៥ នៃរដ្ឋធម្មនុញ្ញ ដើម្បីអនុញ្ញាតឱ្យមានសមភាពអាពាហ៍ពិពាហ៍ស្របច្បាប់ក្នុងគោលបំណងដើម្បីទទួលបានការប្រតិបត្តិយ៉ាងពេញលេញ និងស្មើភាពគ្នាចំពោះបុរសស្រឡាញ់បុរស ស្ត្រីស្រឡាញ់ស្ត្រី អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ និងអន្តរភេទនៅគ្រប់ផ្នែកផ្សេងៗទៀត។

៦. បង្កើតច្បាប់ថ្មីមួយ ដែលធានានូវសមភាព និងហាមឃាត់យ៉ាងជាក់លាក់នូវការរើសអើងចំពោះក្រុមអ្នកស្រឡាញ់ភេទដូចគ្នា។

៧. អនុម័តវិធានការប្រកបដោយប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំង និងផ្តន្ទាទោសចំពោះការរើសអើងនិងអំពើហិង្សាដែលបានជំរុញដោយនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

៨. ត្រឹមដំណាច់ឆ្នាំ២០២៣ ធ្វើការបង្កើតច្បាប់ប្រឆាំងការរើសអើង ដែលធានានូវសមភាព និងការហាមឃាត់យ៉ាងជាក់លាក់រាល់ការរើសអើងគ្រប់ប្រភេទ រួមមាន ដោយសារមូលដ្ឋាននៃសាសនា និន្នាការភេទ អត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និង/ឬលក្ខណៈភេទ។

៩. វិសោធនកម្មមាត្រា៤៥ នៃរដ្ឋធម្មនុញ្ញ ដើម្បីអនុញ្ញាតឱ្យគូស្រករមានភេទដូចគ្នារៀបការបាន។



## ចំណុចវឌ្ឍនភាព

ចាប់តាំងពីឆ្នាំ២០១៩ រដ្ឋាភិបាលបានចាត់វិធានការគួរឱ្យកត់សម្គាល់ និងដាក់ចេញគោលនយោបាយមួយចំនួនដើម្បីដោះស្រាយការរើសអើងដោយមូលដ្ឋាននៃនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ និងការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា រួមមាន៖

- វឌ្ឍនភាពក្នុងការបញ្ចូលមេរៀនអប់រំអំពីផ្លូវភេទទៅក្នុងកម្មវិធីសិក្សានៅតាមសាលារៀន
- ធ្វើបរិយាបន្នស្ត្រីស្រឡាញ់ស្ត្រី អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរយេនឌ័រទៅក្នុងផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រីសម្រាប់ឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ សេចក្តីថ្លែងសាធារណៈរបស់មន្ត្រីរដ្ឋាភិបាលកម្ពុជាដែលជំរុញឱ្យមន្ត្រីរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឪពុកម្តាយ និងគ្រួសាររបស់អ្នកស្រឡាញ់ភេទដូចគ្នា ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជនកុំឱ្យមានការរើសអើង និង
- បង្កើនការផ្សព្វផ្សាយឱ្យទូលំទូលាយអំពីអ្នកស្រឡាញ់ភេទដូចគ្នា និងលើកកម្ពស់ការយល់ដឹងដល់សាធារណជនជុំវិញការទទួលយកអ្នកស្រឡាញ់ភេទដូចគ្នា ក្នុងផ្នែកនៃការអនុវត្តសកម្មភាពលើកកម្ពស់ការយល់ដឹងរបស់អង្គការសង្គមស៊ីវិលក្នុងកិច្ចសហប្រតិបត្តិការជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អាជ្ញាធរមូលដ្ឋាន និងថ្នាក់ជាតិ។




គម្របសៀវភៅដែលមានបញ្ចូលមេរៀនទាក់ទងនឹងនិន្នាការភេទ និងយេនឌ័រ

## ចំណុចនៅពុំទាន់បានអនុវត្ត

ទោះបីជារដ្ឋាភិបាលបានបង្កើតវឌ្ឍនភាពគួរឱ្យសាទរចំពោះការលើកកម្ពស់ និងការពារសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាតាំងពីឆ្នាំ២០១៩ មកក្តី រហូតមកដល់ពេលនេះរដ្ឋាភិបាលពុំទាន់មានវិធានការជាក់លាក់គួរឱ្យកត់សម្គាល់ក្នុងការធ្វើកំណែទម្រង់ច្បាប់ឆ្លើយតបទៅនឹងអនុសាសន៍ដែលទទួលយកទាក់ទងនឹងនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ បង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទនៅឡើយ ដូចជា៖

- ពុំទាន់ធ្វើវិសោធនកម្មមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ ដែលរារាំងសមភាពអាពាហ៍ពិពាហ៍សម្រាប់ដៃគូស្រឡាញ់ភេទដូចគ្នា
- ពុំទាន់អនុម័តច្បាប់ដែលអនុញ្ញាតឱ្យមានការទទួលស្គាល់អ្នកប្តូរយេនឌ័រតាមផ្លូវច្បាប់ ដែលធ្វើឱ្យប៉ះពាល់ដល់ការសម្រេចបានការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់តាមស្វ័យសម្រេចរបស់បុគ្គល
- រដ្ឋាភិបាលនៅពុំទាន់បង្កើតច្បាប់ជាក់លាក់ហាមប្រាមការរើសអើងដោយមូលដ្ឋាននៃនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញទំនោរយេនឌ័រ និង/ឬលក្ខណៈភេទនៅក្នុងក្របខ័ណ្ឌច្បាប់កម្ពុជានៅឡើយ។ ហេតុនេះហើយ អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាបន្តប្រឈមនឹងការរើសអើងផ្នែកច្បាប់ និងសង្គមក្នុងទម្រង់ផ្សេងៗ ដូចជា ក្នុងរង្វង់គ្រួសារ នៅកន្លែងការងារ សាលារៀន និងក្នុងវិស័យសុខាភិបាលជាដើម។





រដ្ឋាភិបាលបានបង្ហាញជំហរ និងធ្វើកិច្ចការមួយចំនួនក្នុងការការពារ និងការលើកកម្ពស់សិទ្ធិស្មើភាពគ្នាសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា ប៉ុន្តែនៅពុំទាន់គ្រប់គ្រាន់នៅឡើយ។ រដ្ឋាភិបាលត្រូវមានវិធានការជាក់លាក់ក្នុងការអនុវត្តអនុសាសន៍នានាទាក់ទងនឹងសិទ្ធិនិន្នាការភេទអត្តសញ្ញាណយេនឌ័រ ការបង្ហាញទំនោរយេនឌ័រ និង/ឬលក្ខណៈភេទ តាមការសន្យាឱ្យបានមុន យូភីអ ជុំបន្ទាប់ ដើម្បីធានាថាសិទ្ធិមនុស្សរបស់អ្នកស្រឡាញ់ភេទដូចគ្នាត្រូវបានការពារយ៉ាងពេញលេញនៅប្រទេសកម្ពុជា៕

ប្រភព:របាយការណ៍រួមយូភីអពាក់កណ្តាលអាណត្តិស្តីពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ (ខែមីនា ឆ្នាំ២០២២)

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights
@CCHRCambodia
@CCHRCambodia
cchrcambodia.org
sithi.org

ខែមេសា ឆ្នាំ២០២២

CC BY NC SA